# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះធ្វើឡើងនៅសៀមរាប , ថ្ងៃទី ០៣ ខែ មិនា ឆ្នាំ២០២២ រវាង ៖

*ភាគីសណ្ឋាគារ* ៖ តំណាងដោយ លោកស្រី **ហម សាឡុន** ថ្ងៃ ខែ ឆ្នាំកំណើត 03-06-1985 អត្តសញ្ញាណ ប័ណ្ណសញ្ជាតិខ្មែរលេខ ៖ 180889813 ចុះថ្ងៃទី 25-05-2016 អាសយដ្ឋាន ៖ ផ្ទះលេខ ផ្លូវ ភូមិ សាលាកន្សែង សង្កាត់ ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ក្រោយនេះហៅគាត់ថា**ភាគី«ក»** ។

*ភាគីបុគ្គលិកសណ្ឋាគារ*៖ តំណាងដោយ ប្រតិភូបុគ្គលិក និងតំណាងបុគ្គលិកមួយចំនួន ក្រោយនេះហៅគាត់ថា **ភាគី«ខ»** ។

**ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចព្រមព្រៀង ស្តីពីការព្យួរកិច្ចសន្យាការងារ ដូចមានខ្លឹមសារខាងក្រោម ៖**

### កម្មវត្ថុ

*ប្រការ ០១*៖ **ភាគី«ក»**យល់ព្រមព្យួរកិច្ចសន្យាការងារឱ្យ ឯ**ភាគី«ខ»**ក៏យល់ព្រមព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៤៥នាក់ (ស្រី ២៥នាក់) នៃសណ្ឋាគារ**ជាតិថាតា** ក្នុងភូមិស្ទឹងថ្មី សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។

### អាណត្តិជួលនៃការព្យួរ

*ប្រការ ០២*៖ អាណត្តិជួលមានរយៈពេល៥៩(ហាសិបប្រាំបួន)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៣ ខែ មិនា ឆ្នាំ២០២២ រហូតទៅដល់ត្រឹមថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០២២ ។

### សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី«ក»

*ប្រការ ០៣*៖ ទោះបីព្យួរកិច្ចសន្យាការងារឱ្យភាគី«ខ»ហើយក៏ដោយ ក៏**ភាគី«ក»**មានសិទ្ធិបន្តកិច្ចសន្យាវិញមុនពេលកំណត់ ក្នុងករណីសណ្ឋាគារមានភ្ញៀវអាចដំណើរការវិញ ដោយ**ភាគី«ក»**ជូនដំណឹងដោយផ្ទាល់មាត់ ឬជាលាយ- លក្ខណ៍អក្សរដល់**ភាគី«ខ»** ។

*ប្រការ ០៤*៖ កាតព្វកិច្ចរបស់**ភាគី«ក»** រួមមាន ៖

៤.ក- រក្សាកិច្ចសន្យាការងារ និងអត្ថប្រយោជន៍ទាំងអស់នៅក្នុងកិច្ចសន្យាកន្លងមក ។

៤.ខ- ធានាដោះស្រាយលិខិតរដ្ឋបាលទាក់ទងនិងការព្យួរកិច្ចសន្យាការងារនេះ ។

៤.គ- មិនធានាខុសត្រូវលើកិច្ចសន្យាបើ **ភាគី«ខ»** មិនមានសុខមាលភាពអាចបំពេញភារៈកិច្ចជូន**ភាគី«ក»** ពេលដែល**ភាគី«ក»**ត្រូវការ ។

៤.ឃ- មិនទទួលខុសត្រូវការប្រព្រឹត្តខុសច្បាប់របស់បុគ្គលក្នុងកំឡុងព្យួរកិច្ចសន្យាការងារនេះទេ ។

សណ្ឋាគារ ជាតិថាតា អង្គរ CHEATHATA ANGKOR HOTEL

## សិទ្ធិ និងភារកិច្ចរបស់ភាគី«ខ»

ប្រការ ០៥៖ មានសិទ្ធិពេញលេញក្នុងស្វែងរកការងារថ្មី និងបញ្ចប់កិច្ចសន្យាការងារជាមួយ**ភាគី«ខ»** ដោយមិនទាមទាសំណងអ្វីៗទាំងអស់ ។

ប្រការ ០៦៖ កាតព្វកិច្ចរបស់**ភាគី«ខ»** រួមមាន ៖

៦.ក- គ្រប់គ្រង ថែរក្សាស្មារតី សុខមាលភាពផ្ទាល់ខ្លួនដើម្បីអាចបំរើការងារបានវិញនៅពេល**ភាគី«ក»**ត្រូវការចូលបំរើការងារវិញ។

៦.ខ- **ភាគី«ខ»**ធានាការចូលរួមដោះស្រាយបញ្ហាទាក់ទង ព៌ត៌មានការងារ និងការព្យួរកិច្ចសន្យាការងារ ។

៦.គ- **ភាគី«ខ»**ធានាថា ខ្លួនមានទំនាក់ជាប់ជានិច្ចជាមួយសណ្ឋាគារ ដើម្បីទទួលរាល់ព៌ត៌មានដែលផ្តល់ដោយសណ្ឋាគារ ។

៦.ឃ- ទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខច្បាប់ ក្នុងករណីមានបាតុភាពខុសនឹងច្បាប់នៅក្នុងពេលព្យួរការងាររបស់ខ្លួន។

ប្រការ ០៧៖ ក្នុងករណីមិនមានលទ្ធភាព រឺសុខភាពមិនល្អ នោះ**ភាគី«ខ»**យល់ព្រមបញ្ចប់កិច្ចសន្យា និងមិនទាមទារយកវិញអ្វីឡើយ ។

## ការបញ្ចប់កិច្ចព្រមព្រៀង

ប្រការ ០៨៖ ក្នុងករណីមានបំណងបន្ត **ភាគី«ក»** ត្រូវជូនដំណឹងឱ្យ**ភាគី«ខ»**យ៉ាងតិច3(បី)ថ្ងៃមុនថ្ងៃបញ្ចប់កិច្ចព្រមព្រៀងឯ**ភាគី«ខ»**ក៏ត្រូវឆ្លើយតបវិញក្នុងរយៈពេល០៣(បី)ថ្ងៃ ។

ប្រការ ០៩៖ នៅពេលបញ្ចប់អាណត្តិ **ភាគី«ខ»**ត្រូវធ្វើការជូន**ភាគី«ក»**វិញ ។

## ការដោះស្រាយវិវាទ និងកែប្រែកិច្ចព្រមព្រៀង

ប្រការ ១០៖ ក/-ករណីមានប្រធានស័ក ប្រទេសមានសង្គ្រាម ឬហេតុកលយុគណាមួយ ដែលជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការអាជីវកម្ម នោះភាគីទាំងពីរ ត្រូវជួបពិភាក្សាគ្នារកដំណោះស្រាយសមស្រប ផ្អែកតាមសភាពជាក់ស្តែង និងស្មារតីយោគយល់គ្នាទៅវិញទៅមក ។

ខ/-ក្នុងករណីមានវិវាទកើតឡើងនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យានេះ ភាគីទាំងពីរត្រូវជួបគ្នា ដើម្បីពិភាក្សាដោះស្រាយឈរលើមូលដ្ឋានស្រុះស្រួលទៅវិញទៅមក។ ប្រសិនបើគ្មានដំណោះស្រាយដោយកិច្ចពិភាក្សាក្នុងរយៈពេលយ៉ាងយូរក្នុងរយៈពេល3(បី)ខែ នោះបញ្ហាវិវាទត្រូវបញ្ជូនទៅដោះស្រាយតាមផ្លូវច្បាប់នៅស្ថាប័នមានសមត្ថកិច្ច ឬតុលាការខេត្តសៀមរាប ក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១១៖ រាល់ការសម្រេចកែប្រែ ឬបន្ថែមប្រការណាមួយពាក់ព័ន្ធនឹងកិច្ចសន្យានេះនឹងចាត់ទុកជាបានការ លុះត្រាតែមានការឯកភាពយល់ព្រមជាលាយលក្ខណ៍អក្សររវាងភាគីទាំងពីរ។

ប្រការ ១២៖ កិច្ចសន្យានេះធ្វើឡើងចំនួន០៥(ប្រាំ)ច្បាប់ មានសុពលភាពចាប់ពីថ្ងៃដែលភាគីទាំងពីរបានផ្តិតមេដៃជាសម្គាល់តទៅ ហើយកិច្ចសន្យានេះត្រូវបានរក្សាទុកដោយ ៖

CHEATHATA ANGKOR HOTEL

– ភាគី«ក» .................................. ចំនួន ០១ច្បាប់

– ភាគី«ខ» .................................. ចំនួន ០១ច្បាប់

– ០៣(បី) សំរាប់មន្ទីរការងារ

**ស្នាមមេដៃស្ដាំ**

**ភាគី«ខ»** **ភាគី«ក»**

CHEATHATA ANGKOR HOT

**ហម សាឡួន**